# ព្រះរាជក្រឹត្យ

នស/រកត/០៩២៣/២១៣៧

## ស្តីពី

## គោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការ នៅក្នុងអង្គការនីតិប្រតិបត្តិ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះ កំណត់អំពីគោលការណ៍ លក្ខខណ្ឌ និងបែបបទសម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការ នៅក្នុងអង្គការនីតិប្រតិបត្តិ ក្នុងគោលបំណងពង្រឹងគោលការណ៍ឋានានុក្រមរដ្ឋបាល សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ ក៏ដូចជា លើកកម្ពស់ប្រសិទ្ធភាពការងាររបស់ទីប្រឹក្សា និងជំនួយការ នៅក្នុងអង្គការនីតិប្រតិបត្តិ។

**មាត្រា២ .-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះទីប្រឹក្សា និងជំនួយការទាំងអស់នៅក្នុងអង្គការនីតិប្រតិបត្តិ លើកលែងតែទីប្រឹក្សា និងជំនួយការរបស់ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ ឬយន្តការនានារបស់រាជរដ្ឋាភិបាល ដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

ព្រះរាជក្រឹត្យនេះមិនមានវិសាលភាពអនុវត្តចំពោះខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី២
## លក្ខខណ្ឌ និងបែបបទនៃការតែងតាំងទីប្រឹក្សា និងជំនួយការ

**មាត្រា៣ .-**

រាជរដ្ឋាភិបាល ព្រមទាំងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល អាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់។

នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី អាចមានទីប្រឹក្សា និងជំនួយការ តាមការកំណត់របស់នាយករដ្ឋមន្ត្រី។

**មាត្រា៤ .-**

ការតែងតាំងមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន ដែលកំពុងកាន់មុខតំណែងនៅទីស្តីការគណៈរដ្ឋមន្ត្រី ឬនៅតាមក្រសួង និងរដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល ឱ្យបំពេញមុខងារជាទីប្រឹក្សា និងជំនួយការ នៅក្នុងអង្គការនីតិប្រតិបត្តិ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តកាតព្វកិច្ចជាមន្ត្រីរាជការឡើយ។

ទីប្រឹក្សា និងជំនួយការ នៅក្នុងអង្គការនីតិប្រតិបត្តិ មិនអាចប្រើប្រាស់នូវបុព្វសិទ្ធិ និងសិទ្ធិអំណាចរបស់ខ្លួន ក្នុងនាមជាទីប្រឹក្សា ឬជំនួយការ ដើម្បីយកទៅអនុវត្តនៅក្នុងមុខតំណែងនៅក្នុងរាជរដ្ឋាភិបាល មុខតំណែងក្នុងក្របខណ្ឌមន្ត្រីរាជការ ឬមុខតំណែងដែលទទួលអាណត្តិតាមការបោះឆ្នោតឡើយ។

**មាត្រា៥ .-**

ការតែងតាំងជាទីប្រឹក្សា និងជំនួយការរបស់រាជរដ្ឋាភិបាល ព្រមទាំងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

-មន្ត្រីក្នុងមុខតំណែងនយោបាយ ឬបុគ្គលផ្សេងទៀតដែលមិនស្ថិតក្នុងក្របខណ្ឌជាមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់រាជរដ្ឋាភិបាល ឬទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួង-រដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល ដោយអាចទទួលបានការផ្តល់ឋានៈស្មើ បន្ថែមលើមុខងារបច្ចុប្បន្ន និងប្រាក់បំណាច់កម្រិតណាមួយបាន។

-មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់រាជរដ្ឋាភិបាល ឬទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួង-រដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល បន្ថែមលើមុខងារបច្ចុប្បន្នបាន ក្នុងលក្ខខណ្ឌដែលមន្ត្រីរាជការសាមីនោះ មិនទទួលបានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់បន្ថែមកម្រិតណាមួយឡើយ។

-មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន មិនអាចត្រូវបានតែងតាំងជាទីប្រឹក្សា ឬជំនួយការនៅទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួង ឬរដ្ឋលេខាធិការដ្ឋានផ្សេងទៀត ក្រៅពីស្ថាប័នសាមីដែលមន្ត្រីរាជការនោះកំពុងបំពេញការងារឡើយ លើកលែងតែមន្ត្រីរាជការនោះ បានលាលែងពីក្របខណ្ឌមន្ត្រីរាជការ ឬត្រូវបានដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម។

-បុគ្គលដែលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជន ឬបុគ្គលដែលទទួលបានគោរមងារឧកញ៉ា អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់រាជរដ្ឋាភិបាល ឬទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួង-រដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាលបាន ក្នុងលក្ខខណ្ឌដែលមិនមានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយឡើយ។

-មេធាវី ឬអ្នកវិជ្ជាជីវៈសេរីផ្សេងទៀត ដែលកំពុងប្រកបវិជ្ជាជីវៈរបស់ខ្លួន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់រាជរដ្ឋាភិបាល ឬទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួង-រដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល ក្នុងលក្ខខណ្ឌដែលមិនមានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយឡើយ។

-មេធាវី ឬអ្នកវិជ្ជាជីវៈសេរីផ្សេងទៀត ដែលមិនប្រកបវិជ្ជាជីវៈរបស់ខ្លួន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់រាជរដ្ឋាភិបាល ឬទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួង-រដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល ដោយទទួលបានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយបាន។

**មាត្រា៦ ៈ**

ការតែងតាំងជាទីប្រឹក្សា និងជំនួយការរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

-មន្ត្រីក្នុងមុខតំណែងនយោបាយ ឬបុគ្គលផ្សេងទៀតដែលមិនស្ថិតក្នុងក្របខណ្ឌជាមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ឬទេសរដ្ឋមន្ត្រី ដោយអាចទទួលបានការផ្តល់ឋានៈស្មើ បន្ថែមលើមុខងារបច្ចុប្បន្ន និងប្រាក់បំណាច់កម្រិតណាមួយបាន។

-មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ឬទេសរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្នបាន ក្នុងលក្ខខណ្ឌដែលមន្ត្រីរាជការសាមីនោះ មិនទទួលបានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់បន្ថែមកម្រិតណាមួយឡើយ។

-បុគ្គលដែលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជន ឬបុគ្គលដែលទទួលបានគោរមងារឧកញ៉ា អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ឬទេសរដ្ឋមន្ត្រី ក្នុងលក្ខខណ្ឌដែលមិនមានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយឡើយ។

-មេធាវី ឬអ្នកវិជ្ជាជីវៈសេរីផ្សេងទៀត ដែលកំពុងប្រកបវិជ្ជាជីវៈរបស់ខ្លួន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ឬទេសរដ្ឋមន្ត្រី ក្នុងលក្ខខណ្ឌដែលមិនមានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយឡើយ។

-មេធាវី ឬអ្នកវិជ្ជាជីវៈសេរីផ្សេងទៀត ដែលមិនប្រកបវិជ្ជាជីវៈរបស់ខ្លួន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ឬទេសរដ្ឋមន្ត្រី ដោយទទួលបានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយបាន។

**មាត្រា៧ .-**

មុខតំណែងជាទីប្រឹក្សា និងជំនួយការរបស់រាជរដ្ឋាភិបាល ព្រមទាំងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល ឬរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី មានវិសមិតភាពជាមួយនឹងមុខងារជាមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន ក្នុងករណីដែលទីប្រឹក្សា ឬជំនួយការនោះ ត្រូវបានតែងតាំងដោយទទួលបាននូវឋានៈស្មើកម្រិតណាមួយ។ ក្នុងករណីនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋានត្រូវចាត់វិធានការក្នុងការដាក់មន្ត្រីរាជការសាមីឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម លើកលែងតែមន្ត្រីរាជការសាមីនោះស្នើសុំលាឈប់ពីមុខតំណែងជាទីប្រឹក្សា ឬជំនួយការវិញ។

**មាត្រា៨ .-**

រយៈពេលដែលមន្ត្រីរាជការត្រូវបានដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម ដើម្បីទទួលមុខតំណែងជាទីប្រឹក្សា ឬជំនួយការដែលទទួលបានការផ្តល់ឋានៈស្មើ ត្រូវបានគិតជាអតីតភាពក្នុងការដំឡើងថ្នាក់ និង/ឬឋានន្តរស័ក្តិ និងអតីតភាពក្នុងការទទួលសោធននិវត្តន៍ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចមន្ត្រីរាជការដែលកំពុងបំពេញការងារក្នុងក្របខណ្ឌដើម។

ក្រោយពេលបញ្ចប់មុខតំណែងជាទីប្រឹក្សា ឬជំនួយការ មន្ត្រីរាជការសាមីត្រូវដាក់ពាក្យសុំចូលបម្រើការងារក្នុងក្របខណ្ឌដើមវិញ។ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋានសាមី ត្រូវទទួលឱ្យចូលបម្រើការងារវិញ ដោយផ្តល់ជូនជាស្វ័យប្រវត្តិនូវឋានន្តរស័ក្តិ និងថ្នាក់ដោយអនុលោមតាមកថាខណ្ឌទី១ ខាងលើនេះ និងប្រាក់បំណាច់មុខងារផ្អែកលើមុខតំណែងជាមន្ត្រីរាជការ ដែលមានមុនការតែងតាំងជាទីប្រឹក្សា ឬជំនួយការ។ មន្ត្រីរាជការសាមីខាងលើ ត្រូវទទួលបាននូវសិទ្ធិអាទិភាពក្នុងការតែងតាំងក្នុងមុខតំណែងដើម ឬមុខតំណែងទំនេរប្រហាក់ប្រហែលនឹងមុខតំណែងដើម ផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាន និងការសម្រេចរបស់ប្រធានស្ថាប័ន។

ឋានៈស្មើនឹងមុខតំណែងក្នុងកម្រិតណាមួយរបស់ទីប្រឹក្សា និងជំនួយការ នៅក្នុងអង្គការនីតិប្រតិបត្តិ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ធ្វើជាមូលដ្ឋាន ទាំងសម្រាប់ការតែងតាំងក្នុងមុខតំណែងមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន ទាំងសម្រាប់ការផ្លាស់ប្តូរ ការបញ្ចូលទៅក្នុងក្របខណ្ឌ និងការដំឡើងឋានន្តរស័ក្តិ និងថ្នាក់នោះឡើយ។

**មាត្រា៩ .-**

ការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងជាទីប្រឹក្សា និងជំនួយការដែលមានឋានៈស្មើអគ្គនាយកឡើងទៅ ត្រូវធ្វើឡើងតាមព្រះរាជក្រឹត្យ ដោយយោងតាមសំណើរបស់នាយករដ្ឋមន្ត្រី។

ការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងជាទីប្រឹក្សា និងជំនួយការដែលមានឋានៈស្មើប្រធាននាយកដ្ឋានឡើងទៅ ត្រូវធ្វើឡើងតាមអនុក្រឹត្យ។

ការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងជាទីប្រឹក្សា និងជំនួយការដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋានចុះក្រោម ត្រូវធ្វើឡើងតាមប្រកាស។

ទីប្រឹក្សា ដែលមិនទទួលបានការផ្តល់ឋានៈស្មើ ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ។ ជំនួយការរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី ដែលមិនទទួលបានការផ្តល់

ឋានៈស្មើ ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។ ជំនួយការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង-រដ្ឋលេខាធិការដ្ឋាន ដែលមិនទទួលបានការផ្តល់ឋានៈស្មើ ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយអនុក្រឹត្យ ឬប្រកាស។ ទីប្រឹក្សា និងជំនួយការ ដែលទទួលបានការតែងតាំងដោយព្រះរាជក្រឹត្យ ត្រូវទទួលបានងារជា **ឯកឧត្តម ឬ លោកជំទាវ**។

នៅពេលដែលតំណែងរាជរដ្ឋាភិបាលត្រូវបានបញ្ចប់ មុខតំណែងជាទីប្រឹក្សា និងជំនួយការរបស់រាជរដ្ឋាភិបាល ព្រមទាំងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋាននានាចំណុះរាជរដ្ឋាភិបាល ក៏ត្រូវបញ្ចប់ផងដែរ។

នៅពេលដែលមុខតំណែងរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី ត្រូវបានបញ្ចប់ មុខតំណែងជាទីប្រឹក្សា និងជំនួយការរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី ក៏ត្រូវបញ្ចប់ផងដែរ។

**មាត្រា១០ .-**

មានតែទីប្រឹក្សា និងជំនួយការដែលមានឋានៈស្មើប៉ុណ្ណោះ ទើបអាចទទួលប្រាក់បំណាច់មុខងារបាន។ ទីប្រឹក្សា និងជំនួយការ មិនអាចទទួលបានប្រាក់បំណាច់មុខងារលើសពីមួយបានឡើយ។

ប្រាក់បំណាច់មុខងារ និងប្រាក់បេសកកម្មរបស់ទីប្រឹក្សា និងជំនួយការ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា១១ .-**

ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃចូលជាធរមាននៃព្រះរាជក្រឹត្យនេះ ទីប្រឹក្សា ជំនួយការ ឬលេខាធិការ នៅក្នុងអង្គការនីតិប្រតិបត្តិ ដែលជាមន្ត្រីរាជការ ដែលត្រូវបានតែងតាំងដោយទទួលបាននូវការផ្តល់ឋានៈស្មើ មុនពេលព្រះរាជក្រឹត្យនេះចូលជាធរមាន ត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខណ្ឌដើម។ ផុតរយៈពេល ៦ (ប្រាំមួយ) ខែនេះ ប្រាក់បំណាច់មុខងារជាទីប្រឹក្សា ជំនួយការ ឬលេខាធិការ ត្រូវកាត់ផ្តាច់ និងជំនួសដោយប្រាក់បំណាច់មុខងារនៅតាមអង្គភាពដើមរបស់មន្ត្រីរាជការនោះវិញ ហើយទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង-រដ្ឋលេខាធិការដ្ឋានសាមី ត្រូវចាត់វិធានការដើម្បីអនុវត្តឱ្យស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការកំណត់ ការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ ដែលមានមុនពេលព្រះរាជក្រឹត្យនេះចូលជាធរមាន នៅមានអានុភាពអនុវត្តបន្តរហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ស្របតាមព្រះរាជក្រឹត្យនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា១៣.-**

សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃពុធ ៦រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០២៣
**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

នស.រកត.០៩២៣.១៥៥៤

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**